**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ៣៩៤៩ អយក.ចក

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

**ជម្រាបជូន**

**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទនីស្តីការក្រសួង**
**-លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** សំណើសុំពន្លឿនការទូទាត់ថវិកាកម្មវិធីពេញលេញរបស់អង្គភាពនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអនុវត្តថវិកាក្នុងឆ្នាំ២០២១។

**យោង ៖** -ប្រកាសអន្តរក្រសួងលេខ ០៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

-សារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** លោក លោកស្រីប្រធាន ជ្រាបថា៖ ចាប់តាំងពីឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ដោយមានអង្គភាពថវិកាចំនួន៦៣(រដ្ឋបាលកណ្តាលចំនួន ៣៨ និងរាជធានី ខេត្តចំនួន ២៥) និងកម្មវិធីចំនួន ៥ ព្រមទាំងវិមជ្ឈការការគ្រប់គ្រងហិរញ្ញវត្ថុជូនអង្គភាពថវិកា ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការទទួលខុសត្រូវនិងលើកកម្ពស់តម្លាភាព គណនេយ្យភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រកបដោយភាពជាម្ចាស់ ហើយស្របតាមផែនការសកម្មភាព និងទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចូលរួមអភិវឌ្ឍន៍សមត្ថភាពបន្ថែមជូនថ្នាក់ដឹកនាំនិងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យយល់កាន់តែស៊ីជម្រៅ ស្តីពីនីតិវិធីនៃការអនុវត្តថវិកា និងបានបង្កើតប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុជូនដល់អង្គភាព ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការពិនិត្យតាមដាន វិភាគ និងវាយតម្លៃ។ ដោយឡែក ការអនុវត្តថវិកាគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសរុបចំនួន ៦៣.៥% បើធៀបនឹងឥណទានកែតម្រូវក្នុងនោះ រដ្ឋបាលកណ្តាលចំនួន ២៨.៦% និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន ៦៨.៣%។ តាមស្ថានភាពជាក់ស្តែងការអនុវត្តថវិកាឆ្នាំ២០២១ មិនទាន់ឆ្លើយតបនិងចំណុចដៅ ដោយមានអត្រាទូទាត់ទាបជាងឆ្នាំ២០២០ កន្លងមក ជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផែនការសកម្មភាព និងសូចនាករគោលដៅរបស់ក្រសួង។ ក្នុងន័យនេះ ដើម្បីពង្រឹងនិងពន្លឿនការអនុវត្តថវិកាឆ្នាំ២០២១ ឱ្យប្រព្រឹត្តទៅទាន់ពេលវេលា និងស្របតាមក្របខណ្ឌច្បាប់គតិយុត្ត ក្រសួងស្នើសុំកំណត់៖



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

១-ប្រធានកម្មវិធី ប្រធានអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡាក្រោមឱវាទក្រសួង ត្រូវចូលរួមជំរុញនិងពន្លឿនរាល់ប្រតិបត្តិការនៃការអនុវត្តថវិកាឱ្យស្របតាមក្របខណ្ឌពេលវេលានិងផែនការសកម្មភាព ព្រមទាំងស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននិងសារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាកំហិត។

២-ការបោះផ្សាយអាណត្តិបើកប្រាក់ និង/ឬអាណត្តិនិយ័តកម្មគ្រប់ប្រភេទចុងក្រោយបង្អស់ ដែលបានចុះហត្ថលេខាអាណាប័កដើមខ្សែ ត្រូវបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុយ៉ាងយូរត្រឹមសប្តាហ៍ទី២ ខែធ្នូ ឆ្នាំ២០២១ ដើម្បីឆ្លងការឯកភាពក្នុងប្រព័ន្ធព័ត៌មានវិទ្យា (FMIS) រីឯអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិក៏ត្រូវបញ្ជូនយ៉ាងយូរត្រឹមដើមសប្តាហ៍ទី៣ ខែធ្នូ ឆ្នាំ២០២១ ដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអប់រំ យុវជន និងកីឡា។ ដោយឡែក ក្នុងករណីអង្គភាពថវិកាបោះផ្សាយអាណត្តិបើកប្រាក់ និង/ឬអាណត្តិនិយ័តកម្ម មិនមានឯកសារគតិយុត្តភ្ជាប់មកជាមួយគ្រប់គ្រាន់ ត្រឹមត្រូវ និងច្បាស់លាស់ នោះក្រសួងនឹងមិនឯកភាពផ្តល់ជូនតាមសំណើសម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៣-ក្នុងករណីការបោះផ្សាយអាណត្តិបើកប្រាក់ និង/ឬអាណត្តិនិយ័តកម្ម ចុងក្រោយបង្អស់របស់អង្គភាពថវិកា មិនទាន់ពេលដូចនឹងចំណុចទី២ខាងលើ ក្រសួងនឹងមិនអនុញ្ញាតឱ្យដំណើរការក្នុងប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ដោយតម្រូវឱ្យប្រើប្រាស់ឥណទានថវិកានៅឆ្នាំបន្ទាប់គឺឆ្នាំ(N+1) ដើម្បីទូទាត់ការចំណាយនេះសម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៤-គ្រប់ប្រធានអង្គភាព ត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវភាពជាម្ចាស់ក្នុងការពិនិត្យតាមដាន និងចូលរួមជំរុញយ៉ាងសកម្មនូវការអនុវត្តថវិកាឱ្យទាន់ពេលវេលា ដើម្បីធានាស្ថិរភាព និងចីរភាពនៃតុល្យភាពចំណាយក្នុងការលើកកម្ពស់សុខុមាលភាពការងាររបស់អង្គភាពសាមី។

៥-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តថវិកា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា តាមការគួរ។

**សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារ .នា.ហិរញ្ញវត្ថុ